# ការសន្យានៃពិធីបុណ្យជ្រមុជទឹក

*« ហេតុអ្វីកូនចង់ទទួលបុណ្យជ្រមុជទឹក ? » លោកប៉ាសួរ ។*

ដោយ ដូរីលីន ខាតជី
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅក្នុង ស.រ.អា. ។*

« ប៉ា តើកូនអាចទទួលបុណ្យជ្រមុជទឹកពេលកូនអាយុប្រាំបីឆ្នាំបានទេ ? » ខេតុន បានសួរ ។

ប៉ា បានងើបមុខឡើង ងាកចេញពីល្បែងដែលពួកគាត់កំពុងលេង ។ « វាជាជម្រើសដ៏ធំ ។ តើវាមិនល្អទេឬអី បើកូនរង់ចាំរហូតដល់អាយុ ១៨ ឆ្នាំ នោះ ? »

ខេតុន បានគិតអំពីរឿងនេះ ។ « ប៉ុន្តែកូនជិតដល់អាយុប្រាំបីឆ្នាំហើយឥឡូវនេះ ។ ហើយអាយុ ១៨ ឆ្នាំនៅយូរណាស់ ! »

ប៉ាបាននៅស្ងៀមមួយសន្ទុះ ។ គាត់បានយកបំណែកល្បែងរបស់គាត់ចេញ ។ « ហេតុអ្វីកូនចង់ទទួលបុណ្យជ្រមុជទឹក ? »

ខេតុន បាននិយាយថា « កូនស្រឡាញ់ព្រះយេស៊ូវ ។ ហើយកូនចង់ធ្វើតាមទ្រង់ » ។

ប៉ាបានមានប្រសាសន៍ថា « នោះជាមូលហេតុដ៏អស្ចារ្យដើម្បីទទួលពិធីបុណ្យជ្រមុជទឹក » គាត់ញញឹម ។ « ប៉ាគាំទ្រកូន ប្រសិនបើនោះជាអ្វីដែលកូនជ្រើសរើស ។ មិនថាកូនមានអាយុប្រាំបីឆ្នាំ ឬ ១៨ ឆ្នាំនោះទេ » ។

ខេតុន បានយកដៃគាត់ឱបប៉ា ។ « អរគុណប៉ា ! »

ប៉ាមិនមែនជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយទេ ។ ប៉ុន្តែពេលខ្លះគាត់ទៅព្រះវិហារជាមួយខេតុន និងម៉ាក់ ។ ហើយនៅពេលខេតុនឡើងនិយាយ ឬច្រៀងជាមួយកុមារផ្សេងទៀតនៅក្នុងការប្រជុំសាក្រាម៉ង់ ប៉ាតែងតែមកជាមួយ ។

បន្ទាប់ពីពួកគាត់លេងល្បែងនេះហើយ ខេតុន បានទៅរកម៉ាក់នៅផ្ទះបាយ ។

គាត់បាននិយាយថា « ប៉ាបានមានប្រសាសន៍ថា កូនអាចទទួលបុណ្យជ្រមុជទឹកបាន នៅពេលកូនអាយុប្រាំបីឆ្នាំ » ។

ម៉ាក់ញញឹម ។ « វាពិតជារំភើបណាស់ ! តើកូនបានគិតថាចង់ឲ្យនរណាធ្វើពិធីបុណ្យជ្រមុជទឹកឲ្យកូនទេ ? »

ខេតុន បានដាក់ចាននៅលើតុ ។ « តើម៉ាក់គិតថាលោកតាអាចធ្វើបានទេ ? លោកតា និងលោកយាយកំពុងបម្រើបេសកកម្មនៅទីក្រុងផ្សេង ។

ម៉ាក់បានមានប្រសាសន៍ថា « យើងអាចសួរគាត់បាន » ។

បន្ទាប់ពីអាហារពេលល្ងាច ខេតុន បានទូរសព្ទហៅជាវីដេអូទៅលោកតា និងលោកយាយនៅលើទូរសព្ទរបស់ម៉ាក់ ។ បន្ទាប់ពីរោទិ៍បានពីរបីដង មុខដែលមានស្នាមញញឹមរបស់គាត់បានបង្ហាញពេញនៅលើអេក្រង់ ។

« ជម្រាប់សួរលោកយាយ ! ជម្រាបសួរលោកតា ! » ខេតុន បាននិយាយ ។ « ទាយទៅមើល ? ចៅនឹងទទួលបុណ្យជ្រមុជទឹកនៅថ្ងៃខួបកំណើតរបស់ចៅនៅឆ្នាំនេះហើយ » ។

« ឱ អស្ចារ្យណាស់! » លោកយាយបានមានប្រសាសន៍ ។

« តើលោកតាអាចធ្វើបុណ្យជ្រមុជទឹកឲ្យចៅបានទេ ? » ខេតុន បានសួរ ។

លោកតាកាន់តែញញឹមខ្លាំងឡើង ។ « តាពិតជាចង់ធ្វើណាស់ » ។

នៅពេលថ្ងៃទទួលបុណ្យជ្រមុជទឹករបស់គាត់មកដល់ ខេតុន បានរៀបចំខ្លួនរួចរាល់ ។ ម៉ាក់ និងប៉ា បានជិះឡានដឹកគាត់ទៅកាន់រោងជំនុំតូចមួយដែលលោកតា និងលោកយាយរបស់គាត់កំពុងបម្រើបេសកកម្មរបស់ពួកគាត់ ។

ខេតុន និងលោកតាស្លៀកពាក់ពណ៌ស ។ ពួកគាត់បានអង្គុយជាមួយគ្នានៅពេលមនុស្សគ្រប់គ្នាកំពុងច្រៀង ។ បន្ទាប់មកម៉ាក់បានឡើងអធិស្ឋាន ។

បន្ទាប់មក ប៉ាឡើងនិយាយ ។ គាត់បានមានប្រសាសន៍ថា « នៅពេលកូនជ្រមុជទឹក កូនសន្យាថានឹងធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ទ្រង់បានបង្រៀនយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។ សេចក្ដីស្រឡាញ់គឺជារបៀបរស់នៅដ៏ល្អបំផុត » ។

ខេតុន បានមើលទៅរូបភាពនៃព្រះយេស៊ូវ ដែលប៉ាកំពុងកាន់ ។

« នៅពេលយើងស្រឡាញ់អ្នកដទៃ វាធ្វើឲ្យពួកគេទទួលអារម្មណ៍ថាមានគេខ្វល់ខ្វាយដល់ខ្លួន ។ វាក៏ជួយឲ្យយើងសប្បាយចិត្ត និងមានសេចក្ដីសុខសាន្តផងដែរ » ។ ប៉ា មើលចំខេតុន ។ « ប៉ាមានមោទនភាពចំពោះកូនណាស់នៅថ្ងៃនេះដែលសន្យាធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ ប៉ាសង្ឃឹមថា ពិធីបុណ្យជ្រមុជទឹករបស់កូនរំឭកកូនឲ្យស្រឡាញ់ព្រះ និងអ្នកដទៃ » ។

ខេតុនបានឱបប៉ាយ៉ាងណែន ។ បន្ទាប់មក ខេតុនបានទៅតាមលោកតាចូលទៅក្នុងអាងជ្រមុជទឹកតូចមួយ ។ ខេតុន បានដាក់ដៃម្ខាងនៅលើស្មារបស់លោកតា និងដៃម្ខាងទៀតនៅលើដៃរបស់លោកតា ។ លោកតា បានពោលពាក្យអធិស្ឋានសម្រាប់ធ្វើពិធីបុណ្យជ្រមុជទឹក ។ បន្ទាប់មកគាត់ជួយបន្ទាបខ្លួនរបស់ខេតុនចូលទៅក្នុងទឹក ។

នៅពេលខេតុន ងើបចេញពីទឹក គាត់ញញឹម ។ គាត់បានធ្វើវាសម្រេចហើយ ! គាត់បានធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ មិនយូរប៉ុន្មាន គាត់ក៏នឹងបានបញ្ជាក់ និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ បន្ទាប់មកគាត់នឹងក្លាយជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខេតុន បានរីករាយក្នុងការរក្សាសេចក្ដីសន្យារបស់គាត់ដើម្បីចងចាំព្រះយេស៊ូវ និងគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ។ ●



ខេតុន បានធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយការទទួលបុណ្យជ្រមុជទឹក ! តើអ្វីទៅជាវិធីមួយដែលអ្នកធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ?

